អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១១

# សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេត

អនុលោមតាមវិធាន ៥៦(២)(ក) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សូមផ្តល់នូវព័ត៌មានដូចខាងក្រោម ៖

១. គិតមកត្រឹមថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ នេះ អង្គភាពគាំពារជនរងគ្រោះបានទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣ ចំនួន ៣១៨ ពាក្យសុំ។

២. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នឹងត្រូវពិនិត្យដោយអង្គភាពគាំពារជនរងគ្រោះដោយ អនុលោមតាមសេចក្តីណែនាំអនុវត្តស្តីអំពីការចូលរួមរបស់ជនរងគ្រោះ មុននឹងមានការបញ្ជូនមកការិយាល័យសហចៅក្រមស៊ើបអង្កេត ។ ដោយយោងទៅលើវិធាន ២៣ ស្ទួន (២) និង (៣) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតនឹងធ្វើការសម្រេចលើភាពអាចទទួលយកបាននៃពាក្យសុំទាំងនោះ យ៉ាងយូរបំផុតនៅពេលចេញដីកាដំណោះស្រាយ។

៣. សហចៅក្រមស៊ើបអង្កេតបានទទួលសំណើមួយរបស់សហព្រះរាជអាជ្ញា សុំឱ្យមានការពន្យារថេរវេលានៃការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចំនួនប្រាំមួយសប្តាហ៍ ។ សេចក្តីសម្រេចស្តីអំពីសំណើសុំនេះនឹងត្រូវធ្វើឡើងក្នុងពេលដ៏ខ្លីខាងមុខនេះ ។

៤. អនុលោមតាមវិធាន ៦៧.១ នៃវិធានផ្ទៃក្នុង នៅចុងបញ្ចប់នៃការស៊ើបសួរ សហចៅក្រមស៊ើបអង្កេតនឹងធ្វើការបង្ហាញនូវគ្រប់អង្គហេតុពាក់ព័ន្ធទាំងអស់ ក៏ដូចជាអំពីការវាយតម្លៃផ្នែកច្បាប់នៃអង្គហេតុនៅក្នុងដីកាដំណោះស្រាយមួយ ដែលមានសំអាងហេតុត្រឹមត្រូវ ។ ដីកាដំណោះស្រាយ គឺជាដីកាសម្រេចមួយដែលនឹងត្រូវធ្វើឡើងជាសាធារណៈ ដូច្នេះគ្រប់បុគ្គលដែលមានចំណាប់អារម្មណ៍នឹងដំណើរការរបស់ អ.វ.ត.ក. ទាំងអស់អាចនឹងទទួលបាននូវដីកានេះ។

លោក **ឌីម សុវណ្ណារ៉ុំ**
មន្ត្រីទទួលបន្ទុកការងារព័ត៌មាន
ទូរស័ព្ទចល័តលេខ +855(0) 12 488 094
ទូរសារលេខ +855(0)23 219 841
សារអេឡិចត្រូនិក dim.sovannarom@eccc.gov.kh

លោក **ឡាស អូលសិន**
មន្ត្រីច្បាប់ទទួលផ្នែកទំនាក់ទំនង
ទូរស័ព្ទចល័តលេខ +855(0) 12 488 023
ទូរសារលេខ +855(0)23 219 841 លេខបន្ត 6169
សារអេឡិចត្រូនិច olsenl@un.org

លោកស្រី**យ៉ូកូមេដា**
មន្ត្រីទទួលបន្ទុកផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ +855(0) 12 488 319
ទូរសារលេខ +855(0)23 219 841 លេខបន្ត 6139
សារអេឡិចត្រូនិក maeday@un.org